**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

===================

# ក្រុមហ៊ុន ធី អ៉រ ស៊ី អេ ហ្គាម៉ិន

## កិច្ចព្រមព្រៀង

ថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០២០ នៅក្រុមហ៊ុន ធី អ៉រ ស៊ី អេ ហ្គាម៉ិន បានបើកកិច្ចប្រជុំមួយតាមរយៈអនឡាញ ក្រោមអធិបតីភាពអ្នកស្រី សុខ ទាំង ជាតំណាងក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារមួយរយៈដោយមូលហេតុដោយសារតែក្រុមហ៊ុនត្រូវបានភ្ញៀវផ្អាកការបញ្ជាទិញសម្លៀកបំពាក់បណ្តាលឲ្យសង្វាក់ផលិតកម្មមិនអាចដំណើរការទៅមុខបានក្នុងរយៈ០២ខែ។

សមាសភាពចូលរួមៈ

1- ភាគីតំណាងក្រុមហ៊ុន

| | |
|---|---|
| - លោកស្រី សុខ ទាំង | ជាតំណាងក្រុមហ៊ុន និងជាប្រធានរដ្ឋបាល និងអ្នកកត់ត្រា |
| - លោក Zhou Yong | អ្នកគ្រប់គ្រងផ្នែកផលិតកម្ម |

2- ភាគីតំណាងកម្មករនិយោជិត

| | |
|---|---|
| - លោក ជៀម កុសល | ជាប្រធានសហជីប |
| - លោក ពេន សារីត | ជាប្រធានសហជីប |
| - លោក ប៉ុល រតនា | ជាប្រតិភូបុគ្គលិក |
| - លោកស្រី នៅ មួយ | ជាប្រតិភូបុគ្គលិក |
| - លោកស្រី ហាន ចន្ធូ | ជាប្រតិភូបុគ្គលិក |
| - លោក សំ ពិសិដ្ឋ | ជាប្រតិភូបុគ្គលិក |

ក្រោយពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងដូចខាងក្រោម ៖

1- ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ចំនួន ១៩៦នាក់ ក្នុងចំណោមកម្មករសរុបចំនួន ១៩៦នាក់ ក្នុងរយៈពេល២ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០។

2- ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុនមិនមានលទ្ធភាពក្នុងការអនុវត្តន៍ការផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករ-និយោជិតទៅតាមសេចក្តីណែនាំលេខ០៤៥/២០ របស់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១៧ មេសា ឆ្នាំ២០២០ ស្តីពីការព្យួរកិច្ចសន្យាការងារ ចំនួន៣០ដុល្លារ និងការផ្អាកបង់ភាគទាន ប.ស.ស សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យការងារ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារកូវីដ-១៩។

3- ចប់ការព្យួរការងារកម្មករនិយោជិត ត្រូវមកចូលធ្វើការនៅកន្លែងដើមវិញ តាមតួនាទីភារកិច្ចរបស់ខ្លួន។

ការប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង១៦:០០នាទី នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ ដដែលក្រោមបរិយាកាសរីករាយ។

ថ្ងៃច័ន្ទ ០៦កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ពស២៥៦៤

ត្រូវនឹងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០

| បានឃើញនឹងឯកភាព | បានឃើញនឹងឯកភាព | |
|---|---|---|
| តំណាង ក្រុមហ៊ុន | តំណាងកម្មករ | |
| សុខ ទាំង | ១. លោក ជៀម កុសល | ជាប្រធានសហជីប |
| | ២. លោក ពេន សារីត | ជាប្រធានសហជីប |
| | ៣. លោក ប៉ុល រតនា | ជាប្រតិភូបុគ្គលិក |
| | ៤. លោកស្រី នៅ មួយ | ជាប្រតិភូបុគ្គលិក |
| | ៥. លោកស្រី ហន ចន្ទូ | ជាប្រតិភូបុគ្គលិក |
| | ៦. លោក សំ ពិសិដ្ឋ | ជាប្រតិភូបុគ្គលិក |